សិក្ខាសាលាស្តីអំពី **ជាតិខ្មែររុងរឿង**

**ប្រធានសិក្សារ** ៖ ការថែររក្សាជាតិខ្មែរ(នយោបាយនៃការគ្រប់គ្រងជាតិដើម្បីបណ្តុះបណ្តាលកម្លាំង និង គំនិតជាតិឲ្យបានគង់វង្សនិងរុងរឿង)

**អំណោរគុណ** :

ភិក្ខុសង្ឃ ឯកឧត្តម លោកលោកស្រី និង បងប្អូនរួមជាតិជាទីគោរព។

ខ្ញុំមានកិត្តិយសព្រមនិងសេចក្តីរីករាយចូលរួមចំណែកក្នុងឋានៈជាអ្នកធ្វើអន្តរាគមន៍ក្នុងសិក្ខាសាលាថ្ងៃនេះ ជាមួយឥស្សរជនដែលខ្ញុំតែងទុកលោកជាឧត្តមជន និងជារៀមច្បងគួរជាទីរាប់អាន។ ជាពិសេសទៀត ខ្ញុំមានសេចក្តី រំជួលចិត្ត ជាអតិបរមា ដែលបានមកធ្វើអន្តរាគមន៍នៅចំពោះមុខអស់លោក លោកស្រី ដែលជា ***សវនកៈកា*** ដឹងការ ឮច្បាស់ អំពីបច្ចុប្បន្នភាពស្រុកខ្មែរយើង ហើយ សុខចិត្ត ចំណាយពេលវេលា ដ៏ថ្លៃថ្លាចូលរួមចំណែក ក្នុងការពិភាក្សាស្វែងរកពន្លឺគំនិតស្មារតីជាតិ។ ក្នុងចំណុចនេះហើយ ខ្ញុំសូមអភ័យទោសទុកជាមុនចំពោះលោកលោកស្រី នូវគំនិតណារមួយរបស់ខ្ញុំ ដែលបេះពាល់ដល់ចិត្តគំនិតដ៏ខ្ពង់ខ្ពស់របស់អស់លោក។ អន្តរាគមន៍របស់ខ្ញុំនៅទីនេះ គឺគ្រាន់ជាចំណែកដ៏តូចមួយ ក្នុងផ្នែកគំនិតជាតិ ក្នុងឋានៈជាកូនខ្មែរសាមញ្ញម្នាក់ មានចិត្តចង់ចូលរួមចំណែក ក្នុងការពិភាក្សា រឿងជាតិ តែប៉ុណ្ណោះ។ ខ្ញុំជឿជាក់ថា សិក្ខាសាលានេះទៀតរៀបចំឡើង ក្នុងគំនិតសេរី លទ្ធិប្រជាធិបតេយ្យ និងភាតរភាព ហើយ ការពិភាក្សា នេះសោត គឺឋិតនៅ ក្នុង មហាគ្រួរសារខ្មែរ ដែលជា សង្គម មានសេក្តីត្រាប្រណី ជាខ្លឹមសង្គម។

**សេចក្តីផ្តើម** :

ការបារម្មណ៍រជាអចិន្ត្រៃយ៍របស់ប្រជាជនខ្មែរ លើអានាគតជាតិមិនទៀងទាត់ជា ការបារម្មណ៍មួយជិត ក្នុងស្មារតីខ្មែរជានិច្ចព្រោះរូបភាពនៃ ***វិនាជកម្មជាតិ*** នៅមានរស់ររឿកនៅឡើយ។ ការបារម្មណ៍នេះមាន ***ប្រពលកម្ម*** កាន់តែខ្លាំងខ្លា ក្នុងរបបប្រល័យពូជជាតិឯង “ខ្មែរក្រហម” ក្នុងរយៈពេល ឆ្នាំ១៩៧៥ដល់១៩៧៨ និងការកាន់កាប់យោធាយៀណាម នៅស្រុកខ្មែរ ក្នុងរយៈពេល ឆ្នាំ១៩៧៩ដល់១៩៨៩។ នយោបាយផ្សះផ្សាជាតិររៀងយុទ្ធការីខ្មែរទ្វេភាគី ក្រោមការដឹកនាំ អ.ស.ប. នាឆ្នាំ១៩៩១ នាំសន្តិភាពដល់ប្រជាពលរដ្ឋខ្មែរពិត តែក្នុងសន្តិភាពនេះមិនមានការរ៉ាប់រងនៅឡើយនូវ និរន្តរាយភាព និង សេរីភាព ជូនចំពោះប្រជាជនខ្មែរ។

បុព្វហេតុនៃការបារម្មណ៍នេះមានធាតុពីរយ៉ាង៖ ១-ល្បិចប្រយុទ្ធ វាតទឹកដី ពីសំណាក់ប្រទេសជិតខាង, ២-សេចក្តីសង្ស័យលើការរួបរួមខ្មែរនឹងខ្មែរនៅ ចំពោះភយន្តរាយជាតិ។ យើងអាចសួរ ជាសំនួរមួយថា៖ ភាពខ្វះសាមគ្គីភាពខ្មែរ កើតមកពីល្បិចវាតទឹកដីបរទេស ឬក៏ល្បិចវាតទឹកដីបរទេស កើតមកពីភាពខ្វះសាមគ្គីភាពខ្មែរ ?

ខ្មែរយើងតែងយកសម័យអង្គរជាយោង នៃភាពរុងរឿងជាតិ។ ស្ទើរតែគ្រប់សេចក្តីថ្លែងការ របស់អ្នកដឹកនាំជាតិគ្រប់ជំនាន់តែងតែរំឭកជានិច្ចនូវអតិកាលដ៏កិត្តិគុណនេះ។ ភ័ស្តុតាងមានសោតទៀតលើទង់ជាតិគ្រប់របបនយោបាយ គេតែងយករូបប្រាសាទអង្គរជានិមិត្តរូប និង កិត្យានុភាព

ជាតិខ្មែរ។ យើងអាចសួរជាសំនួរមួយថា ៖ តើអត្តសញ្ញាណជាតិខ្មែរយើង គឺចិតនៅលើ និមិត្តរូប ប្រាសាទអង្គរ នោះឬ ? ចម្លើយច្បាស់ជាថាមែន ព្រោះកាលណា គេឃើញ រូបអង្គរ គេតែងស្គាល់ថា ជាជាតិខ្មែរភ្លាម។ ចំណុចនេះជាចំណុចពិត ឥតមាននរណា ប្រកែកបាន នោះឡើយ។

តែយើងអាចសួរជាសំនួរមួយទៀតថា៖ ពីសតវត្សទី១៦ដល់សតវត្សទី១៩ជាតិខ្មែរថ្លាក់ ក្នុងអត្តង្គត លុបបាត់ក្នុងសតិជាតិនៃភាពរុងរឿងពីអតីតកាលខ្លួន តើខ្មែរនៅមានអ្វីជាគ្រឹះជាតិដើម្បីឧត្តរជីវិត នៃប្រជាជាតិខ្លួន ? យើងអាចឆ្លើយបានថាមាន៖ ភាសា-សាសនា និងប្រពៃណី។ គ្រឹះទាំងបី នេះជា ខែលទប់ទល់នូវ ***វិត្ថារកម្ម*** ទឹកដី និងវប្បធម៌ ពីសំណាក់ប្រទេសជិតខាង។ គេតែង និយាយថា បើគ្មានអត្តរាគមន៏បារាំង នាឆ្នាំ១៨៦៣ នគរខ្មែរយើង ត្រូវប្រទេសជិតខាង លេបបាត់ទៅហើយ។ ចំពោះខ្ញុំផ្ទាល់ ខ្ញុំយល់ឃើញថាបារាំងជួយថែរក្សាជាតិខ្មែរបាន ដោយសារ ខ្មែរយើងមានគ្រឹះជាតិមាំមួន ដែលគេ អាចទុកថាជា រដ្ឋ-ជាតិ មួយពិត។ យើងដឹកថា ទោះបី ប្រទេសជិតខាងធ្វើ ***ឧបសម្ព័ន្ធ*** ទឹកដីខ្មែរ តែ ជនជាតិខ្មែរយើង រស់នៅលើទឹកដីទីនោះ នៅតែ និយាយភាសា និង គោរពប្រពៃណីខ្មែរ ជានិច្ច។ ជាតិ ដែលធ្លាប់មានអារ្យធម៏ខ្ពង់ខ្ពស់ តែងតែ មាន ***អង្គបដិបក្ខ*** ការពារខ្លួនជានិច្ច។

**<u>ការអធិប្បាយ</u>** :

ក្នុងសាវតាជាតិខ្មែរ តើយើងបានកត់សំគាល់អ្វីខ្លះ ដែលអ្នកដឹកនាំជាតិគ្រប់ជំនាន់ធ្វើ នយោបាយ ថែរក្សានិងការពារជាតិ។ សន្ធិសញ្ញាអាណាព្យាបាលបារាំងនាឆ្នាំ១៨៦៣- នយោបាយអព្យា ក្រឹតរបស់ សម្តេច ន.ស៊ីហនុ- ការប្រកាសបង្កើតរបបសាធារណៈរដ្ឋនាឆ្នាំ១៩៧០- ជ័យជំនះ ខ្មែរក្រហមនាឆ្នាំ១៩៧៥- សន្ធិសញ្ញាអាណាព្យាបាលយៀកណាមនាឆ្នាំ១៩៧៩- សន្ធិសញ្ញា អន្តជាតិទីក្រុងបារី ស្តីពីសន្តិភាពកម្ពុជានាឆ្នាំ១៩៩១ តើយើងទុកចំណុចទាំងនោះជានយោបាយ ថែរក្សា និង ការពារជាតិខ្មែរបានឬទេ ?

អ្វីដែលអ្នកដឹកនាំខ្មែរបានធ្វើ តាំងពីឆ្នាំ១៨៦៣ ដល់បច្ចុប្បន្នកាល យើងសង្កេតឃើញ ដូចពាក្យ ខ្មែរគេនិយាយថា “បានត្រឹមតែឡើងមិនបានបេះ បានត្រឹមតែប្រឡេះមិនបានស៊ី” អ្នកដែលបាន ស៊ី គឺប្រទេសយួននិងសៀមឯណោះ។ នេះហើយជា ***សោកនាដ្ឋកម្ម*** ខ្មែរ !

តែយើងដឹងថា ការថែរក្សាឬការការពារជាតិ មិនគ្រប់គ្រាន់សំរាប់ជាតិនោះឡើយ ព្រោះថាជាតិ និមួយៗ ត្រូវការសេចក្តីចំរើន ដើម្បីសុខុមាលភាពរបស់ប្រជាពលរដ្ឋ។ សុខុមាលភាពកើតមាន បានលុះត្រាជាតិ មានសេដ្ឋកិច្ចជាតិចម្រើន ប្រជាពលរដ្ឋមានចំណេះវិជ្ជា និងមាន សុខភាព ក្នុងផ្លូវកាយ និងផ្លូវសតិ។ សុខុមាលភាពប្រជាពលរដ្ឋ ជាសញ្ញានៃភាពសម្បូណ៏របស់ជាតិ។ គ្រប់របបនយោបាយណា មិនយកចិត្តទុកដាក់ក្នុងការរក សុខុមាលភាពដល់ប្រជាពលរដ្ឋ មិន អាចរស់គង់វង់នោះឡើយ លើកលែងតែរបបនយោបាយនោះប្រកាន់លទ្ធិផ្តាច់ការ ទុកប្រជា ពលរដ្ឋ ជាទាសៈ របស់របប។

យើងដឹងថាការថែរក្សាជាតិ ជាភារកិច្ចរបស់ប្រជាពលរដ្ឋនឹងរដ្ឋ។ ប្រជាពលរដ្ឋជាកម្លាំងជាតិ ឯចំណែករដ្ឋជាគ្រោងឆ្អឹងរបស់ជាតិ។ ក្នុងរបបលទ្ធិប្រជាធិបតេយ្យ ប្រជាពលរដ្ឋជាអ្នកជ្រើសតាំងអ្នកដឹកនាំជាតិ ហើយអ្នកដឹកនាំជាតិជាអ្នកគ្រប់គ្រងជាតិប្រើអំណាចរដ្ឋ ក្នុងនាមប្រជាពលរដ្ឋសំរាប់ប្រជាពលរដ្ឋ។ ដូច្នេះអ្នកដឹកនាំជាតិ មានករណីយកិច្ចស្វែងរក ការជឿនលឿនដល់ជាតិសំរាប់សុភមង្គល ដល់ប្រជាជននិមួយៗ និង សំរាប់ប្រយោជន៍រួម របស់ប្រជាពលរដ្ឋ។
យើងដឹងថាស្រុកខ្មែរនាបច្ចុប្បន្ន ជាស្រុកមួយរស់ក្នុង ***ឥទ្ធិពល*** នៃកម្លាំងពិភពលោក និង សេដ្ឋកិច្ចភូមិភាគ ដូចប្រទេស ឯទៀតៗ ក្នុងលោកយើងនេះ។
យើងសួរថា ក្នុង អានុភាពនេះ តើ ***អង្គបដិបក្ខ*** (anticorps) ដែលមានក្នុង អង្គសង្គមខ្មែរ អាចការពារអ្វី ដែលជាគ្រឹះខ្មែរបានដែរឬទេ ?

និយាយអំពីការថែរក្សា ឬ ការពារជាតិខ្មែរ គួរយើងដឹងឲ្យច្បាស់ថាអ្វីទៅដែលជា ***ភយន្តរាយ*** របស់ជាតិខ្មែរ។ លោកនួនឃឿន អ្នកប្រវត្តិសាស្ត្រខ្មែរមួយរូប នាឆ្នាំ១៩៧០ បានសរសេរសៀវភៅមួយ មានចំណងជើងថា « ដំណើរឆ្ពោះទៅទិសខាងលិច-ឥណ្ឌូចិន ឆ្នាំ២០០០» ក្នុងគោលបំណង បង្ហាញ តាមការយល់ឃើញរបស់លោក ពីគ្រោះថ្នាក់អាចមានដល់ អាយុជីវិតជាតិខ្មែរ គ្រោះថ្នាក់នោះ មានមកពី ប្រទេសជិតខាង មានប្រទេសថៃឡង់ និង ប្រទេសយៀកណាម។ កត្តាច្រើន ដែលនាំឲ្យ លោក នួនឃឿន យល់ឃើញថា ប្រទេសទាំងពីរនេះជា “គ្រោះថ្នាក់” ដល់ខ្មែរ ៖ ចំនួនប្រជាពលរដ្ឋគេ មានច្រើនជាងស្រុកខ្មែរ “សេដ្ឋកិច្ចគេ មានការជឿនលឿន” នយោបាយសិក្សាធិការជាតិគេ ធ្វើការបណ្តុះបណ្តាលប្រជាពលរដ្ឋគេ ឲ្យមានការចេះដឹងគ្រប់វិស័យ។ តែលោក នួនឃឿន ធ្វើការ បញ្ជាក់ថាគ្រោះថ្នាក់នេះមិនទុកជាភាព ចៀសពុំរួច សំរាប់ជាតិខ្មែរនោះឡើយ បើសិនណាជាតិខ្មែរមាននយោបាយ ធ្វើអភិវឌ្ឍន៍សេដ្ឋកិច្ច ឲ្យជឿនលឿន សំរាប់ទុប ***ឥទ្ធិពល*** សេដ្ឋកិច្ចប្រទេសជិតខាង - បើសិនណាជាតិខ្មែរ មាននយោបាយ សិក្សាធិការជាតិ បណ្តុះបណ្តាលប្រជាពលរដ្ឋខ្លួន ឲ្យមានការចេះដឹង សំរាប់ ធ្វើអភិវឌ្ឍន៍សេដ្ឋកិច្ច និងសំរាប់ ការពារអ្វីដែលជាគុណសម្បត្តិខ្មែរ។ នយោបាយទាំងនេះ អាចមានបានគឺ ចិតនៅលើឆន្ទៈ អ្នកដឹកនាំជាតិ តែប៉ុណ្ណោះ។

គ្រោះថ្នាក់ជាតិខ្មែរ អាចមានមួយទៀត តែលើកនេះ គឺចេញពីចរិតខ្មែរតែម្តង។ ក្នុងបញ្ហានេះ នាឆ្នាំ១៩៧៣ លោក ប៉ុណ្ណចន្ទម៉ុល ជាអ្នកនយោបាយខ្មែរម្នាក់ បានសរសេរសៀវភៅមួយដែរមានចំណងជើងថា “ចរិតខ្មែ” ។ ក្នុងសៀវភៅនេះ លោកចង់បង្ហាញថា អ្នកដឹកនាំខ្មែរច្រើនមាន ចរិតចង្រៃដល់ជាតិ ដូចយ៉ាង ៖ គំនិតសងសឹងសួរពូជ- គំនិតផ្តាញ់ផ្តាល-គំនិតលោភពង្រេចពង្រើល- គំនិតចង្រៃ។ គំនិតទាំងអស់នេះជាគុណវិបត្តិសំរាប់ជាតិខ្មែរ នាំឲ្យជាតិ ធ្លាក់ក្នុងអត្តង្គត នាំឲ្យប្រទេសជិតខាងឆ្លៀតទាញគុណប្រយោជន៍ សំរាប់ជាតិគេ។ ដើម្បីជាតិរុងរឿង លោកប៉ុណ្ណចន្ទម៉ុលធ្វើប្រសិទ្ធពរដល់អ្នកដឹកនាំជាតិ ឲ្យបោះបង់ចរិតចង្រៃទាំងឡាយ

នោះជាស្ពាន។ សង្គមខ្មែរក្នុងឧត្តរកាល ក៏ដូចក្នុងបច្ចុប្បន្នកាល ត្រូវការអ្នកដឹកនាំ ជា ***វិនាយក*** របស់ជាតិ មានគុណធម៌ មានប្រាជ្ញា ជាបណ្ឌិត មានសមត្ថកិច្ច ក្នុងកិច្ចការជាតិ។ វិច័យរបស់បុព្វបុរសទាំងពីរខាងលើនេះ យើងអាចយកជាយោងមួយ សំរាប់ធ្វើការ ពិចារណារបស់យើង អំពី នយោបាយ ថែរក្សា និងការពារជាតិខ្មែរ។

យើងដឹងថា កាលណាយើងលើកយកបញ្ហាទាំងឡាយដែលមាននៅស្រុកខ្មែរបច្ចុប្បន្ន យើងតែងជួបប្រទេះ នូវមតិពីរ ផ្ទុយគ្នាស្រឡះ។ ម្នាក់មើលឃើញថាស្រុកកំពុង មានភាពជឿនលឿន ម្នាក់ទៀត មើលឃើញថាស្រុកកំពុងឈាន ទៅរកការបាត់បង់ អត្តសញ្ញាណជាតិ ឬធ្លាក់ក្នុងគ្រោះថ្នាក់ ដល់អាយុជីវិតជាតិ។ បើយើងនៅជាអ្នក អព្យាក្រឹត ហើយធ្វើវិភាគ ក្នុងភាព មិនលំអៀង យើងអាចយល់បានថា មតិទាំងពីរនេះ មិនសុទ្ធតែខុសទាំងអស់ ហើយក៏មិនសុទ្ធតែត្រូវទាំងអស់នោះដែរ ល្គឹកណា មតិទាំងពីរនេះ ឋិតនៅក្នុង គំនិត ការពារប្រយោជន៍ជាតិ ដូចគេតែង ចំណាំនិយាយថា មនុស្សពីរនាក់ មើលឃើញកែវតែមួយផ្ទុយគ្នា «កែវមានទឹកពាក់កណ្តាល កែវខ្វះទឹកពាក់កណ្តាល»។ ផ្ទុយទៅវិញ ការដែលយើងមានការ ព្រួយបារម្ភណ៍ គឺ នៅពេលណាដែល ជនជាតិខ្មែរយើង ធ្វើគធ្វើថ្លង់នៅ ចំពោះមុខគ្រោះថ្នាក់ជាតិខ្លួន និងឈរមើលជា ទស្សនីកជនដូចសម័យលង្វែក។ ខ្មែរមានមតិក្នុងបញ្ហាជាតិជាការចូលរួមចំណែកមួយ ក្នុងការថែរក្សាជាតិខ្មែរ។

ជាបឋមការថែរក្សាជាតិខ្មែរ ជាបេសកកម្មរបស់បុគ្គលខ្មែរម្នាក់ៗ។ នៅមុខភារៈកិច្ចដ៏ទូលំទូលាយនេះ យើងយល់ឃើញថាខ្មែរម្នាក់ៗ ត្រូវមានគំនិតមួយថ្មីអំពីមនុស្សលោក និងភារៈកិច្ច របស់ខ្លួនលើ ជោគវាសនារបស់ជាតិ ៖ ជនជាតិខ្មែរ កើតមកមិនមែនសំរាប់ តែរណេបរណើប ដើម្បីឲ្យគេសប្បាយចិត្តនោះទេ។ ខ្មែរប្រាថ្នាទៅជាមនុស្សពេញលក្ខណៈ មានកិត្តិយស មានសិទ្ធិសេរីភាព មានកាតព្វកិច្ច ជាប្រជាជន។ ជីវិតខ្មែរមានដម្លៃដាច់មុខ ដែលសង្គមទទួលស្គាល់ ហើយ គោរពពេញទី ជាពិសេសក្នុងពលិកម្មសំរាប់ប្រទេសជាតិ។ ជីវិតខ្មែរមិនមែនគ្រាន់តែសំរាប់រៀប ចាំឲ្យបានទៅនិព្វាននោះឡើយ។ គឺជាឱកាសមួយដែល នាំឲ្យមនុស្ស រកសុភមង្គលដល់ខ្លួនឯង និង សុភមង្គល ឲ្យសង្គមជាតិ។
វិចារណៈញាណ សម្បជញ្ញៈ គំនីតភ្លឺស្វាង យល់សមុទ្ទយៈ កំចាត់អវិជ្ជា ស្គាល់បុព្វហេតុដែលបណ្តាលឲ្យជាតិ និងប្រទេសស្រុតច្បុតចុះ ពោលគឺ សម្មាទិដ្ឋិ របស់ព្រះសម្មាសម្ពុទ្ធ ចាត់ជាវិភា (ពន្លឺ) បំភ្លឺជាចង្កូត ជាមគ្គុទេសក៏ ដឹកនាំខ្លួនឲ្យក្លាយ ជាមនុស្សពេញលក្ខណៈ ធ្វើមនុស្ស ***ភាវូបនីយកម្ម*** ខ្លួនឯង ជាដំណើរទៅរក ឥស្សរភាព ជាមាគ៌ា ថែរក្សានិងការពារជាតិខ្មែរ។
ជនជាតិខ្មែរមិនត្រូវផ្ញើ អាយុជីវិតខ្លួនលើជាតិដ៏ទៃ ផ្ទុយនឹងតម្រាស់ព្រះពុទ្ធអង្គឡើយ ៖ "អត្តាហិ អត្តនោនាថោ" ដែលជាឱវាទព្រះបុរុមគ្រូសាស្រ្តាចារ្យ។ គំនិតថ្មីកើតមានបាន ពីឆន្ទៈខ្មែរម្នាក់ៗ និងការអប់រំជាតិ ដែលជាភារៈកិច្ច របស់រដ្ឋខ្មែរ។
រដ្ឋខ្មែរជារដ្ឋមួយដែលមានសិទ្ធិមនុស្ស និងសិទ្ធិប្រជាជន ត្រូវទទួលការធានាអះអាងជានិច្ច ជានិតិរដ្ឋដែលមាន ការបែងចែកអំណាចធំៗបីគឺ នីតិបញ្ញាតិ នីតិប្រតិបត្តិ និងតុលាការ។

**ការអប់រំជាតិ :**

ការអប់រំជាតិត្រូវ ឋិតនៅក្នុងសមត្ថកិច្ចអាជ្ញាធររដ្ឋ។ ក្នុងច្បាប់ស្តីពីការអប់រំ ប្រកាសឲ្យប្រើ នាថ្ងៃទី១៩ខែតុលាឆ្នាំ ២០០៧ ក្នុងមាត្រា២ ស្តីពី **គោលបំណង** មានសរសេរថា៖

“ច្បាប់មានគោលបំណងអភិវឌ្ឍធនធានមនុស្សដោយផ្តល់ការអប់រំ ពេញមួយជីវិត សម្រាប់ទាំងអស់គ្នា ដើម្បីឲ្យអ្នកសិក្សាទទួលនូវចំណេះដឹងជំនាញសមត្ថភាព សេចក្តីថ្លៃថ្នូរអាកប្បកិរិយាប្រកបដោយសីលធម៌សំដៅជំរុញឲ្យអ្នកសិក្សាស្គាល់ស្រឡាញ់រួមចំណែកការពារ អត្តសញ្ញាណជាតិវប្បធម៌ជាតិ និង ភាសាជាតិ”

ក្នុងមាត្រា៣១ ស្តីពី **សិទ្ធិនិងករណីយកិច្ចអប់រំ** មានសរសេរថា ៖

“ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិទទួលការអប់រំយ៉ាងតិច៩(ប្រាំបួនឆ្នាំ)ប្រកបដោយគុណភាព ដោយឥតបង់ថ្លៃនៅសាលារៀនសាធារណៈ។ ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រនិងវិធានការជាជំហានៗដើម្បីធានាឲ្យប្រជាពលរដ្ឋគ្រប់រូបទទួលបានការអប់រំប្រកបដោយគុណភាពស្របតាមបទប្បញ្ញត្តិដែលមានចែងក្នុងច្បាប់នេះ”។

យោងលើច្បាប់ស្តីពីការអប់រំ យើងឃើញមាន ឆន្ទៈនិងមហិច្ឆិតា ពីសំណាក់រដ្ឋបច្ចុប្បន្ន រកការបណ្តុះបណ្តាល កម្លាំងនិងគំនិតជាតិ។ ត្រង់ថាវិស័យអប់រំខ្មែរបច្ចុប្បន្ន មានប្រសិទ្ធិភាពស្របតាមឆន្ទៈនិងមហិច្ឆិតាដែលមានក្នុងច្បាប់វិជ្ជមាន ការនេះខ្ញុំមិនធ្វើវិនិច្ឆ័យអ្វីនោះទេ ដើម្បីជៀសកុំឲ្យ មានវិប្រត្តិបត្តិ (ជម្លោះ) គំនិត ព្រោះភារៈកិច្ចនេះឋិតនៅលើសម្បជញ្ញៈ និងវិបស្សនា របស់ ខ្មែរម្នាក់ៗ។ ដូចយើងមើលឃើញ “កែវមានទឹកពាក់កណ្តាល កែវខ្វះទឹកពាក់កណ្តាល” នោះឯង។

យើងគ្រន់តែសួរសំនួរមួយថា តើរដ្ឋាភិបាលបច្ចុប្បន្នមានមធ្យោបាយ និង ធនធានអ្វី ដើម្បី រកគុណភាព ក្នុងវិស័យអប់រំយុវជនខ្មែរ ?

សេចក្តីចេះដឹង របស់ប្រជាពលរដ្ឋ ជាដំណាក់ការណ៍ដំបូង សម្រេចបានជា ភាពរុងរឿងជាតិតាមផ្លូវបញ្ញា។ ដូចកាព្យខ្មែរបុរាណមួយ ស្តីពីវិជ្ជា ដំណាលថា៖ វិទ្យាជាទ្រព្យ ប្រើបាន គ្រប់សព្វ លើសទ្រព្យនានា អ្នកមានទ្រព្យស្រាប់ អាប់ឥតវិជ្ជា មិត្រភ័ក្តិផងគ្នា គេច្រើនមើលងាយ។ល។

ក្នុងវិស័យការចេះដឹងរបស់ប្រជាពលរដ្ឋនេះ យើងលើកជាឧទាហរណ៍រឿង “ព្រះគោព្រះកែវសម័យបន្ទាយលង្វែ” មកដំណាលជំរាបថា សម័យនោះខ្មែរយើងចាញ់សង្គ្រាមសៀម ហើយសៀមគេយកគោទិព្វខ្មែរទៅស្រុកគេ ក្នុងពោះគោនោះ ពាក្យដំណាលថាជាបណ្ណាល័យនៃវប្បធម៌ខ្មែរ គឺគ្មានអ្វីក្រៅពីការចេះដឹងខ្មែរនោះឡើយ។ ការបាត់បង់ការចេះដឹងនាំឲ្យខ្មែរជំនាន់ក្រោយបាត់បញ្ញា រហូតភ្លេចអស់នូវអតីតកាលជាតិខ្លួនអស់ច្រើនសតវត្ស។ ***វិបាក*** នាំឲ្យខ្មែរបាត់ក្បួន លែងមានអ្វីជា សតិសម្បជញ្ញ ជាពន្លឺបំភ្លឺផ្លូវ ហើយគ្មានព្រលឹងក្នុងខ្លួនទេ គ្មានការទុកចិត្ត និងជំនឿលើខ្លួនឯង គិតតែវង្វេងវង្វង់ លង់ទ្រនេស បើកទ្វារប្រទេសបញ្ចូលសត្រូវគ្រប់ទិសឲ្យមកប្រល័យនិងភ្លន់ជាតិ ទឹកដីឯង ប្លន់យកអំណាច នាំឲ្យប្រជារាស្ត្រធ្លាក់ខ្លួនជាទាសភាព បរទេសទឹមដូចសត្វពាហណៈ អស់ច្រើនសតវត្ស។ ភាពវង្វេងនេះ អ្នកប្រាជ្ញនយោបាយហៅថា “អវិជ្ជា”។

**សេដ្ឋកិច្ច** :
មនុស្សត្រូវចាំបាច់មានការងារ មានរបររកស៊ី សំរាប់ចិញ្ចឹមជីវិតប្រកបដោយសេចក្ដីថ្លៃថ្នូរ។ វិជ្ជាជីវៈនិងការងារ ជាគូរដែលរដ្ឋជាអ្នកគិតគូរ។ មនុស្សមានវិជ្ជាជីវៈឥតមាន ការងារ ធ្វើនាំបង្កើតមនោសញ្ចេតនាឥតអានុភាពនៅចំពោះមុខអានាគតរបស់ខ្លួន។ ក្នុងនគរមួយ ដែលមាន អត្រានិកម្មជនខ្ពស់ ជាប្រទេស ឧនាភិវឌ្ឍន៍។ ក្នុងប្រទេសបែបនេះ ប្រជាពលរដ្ឋ ច្រើនរស់ដោយជំនួយអង្គការមនុស្សធម៌។ ការរស់បែបនេះគ្មាននាំនូវភាពចម្រើនអ្វីដល់ជាតិនោះឡើយ។
យើងដឹងថាសេដ្ឋកិច្ចជាអ្នកបង្កើតការងារ។ សេដ្ឋកិច្ចចំរើននៅក្នុងបុរី ដែលមានខ្មែរសេណីជំនាញច្រើនក្រៃ មានសាមគ្គី ជាហេតុបច្ច័យញ៉ាំងរដ្ឋឲ្យថ្លៃ។ រដ្ឋខ្មែរថ្លៃជារដ្ឋមាន មធ្យោបាយថែរក្សា និងការពារជាតិខ្មែរ។
ការធ្វើអភិវឌ្ឍន៍សេដ្ឋកិច្ចឲ្យចំរើន ជាមាគ៌ានាំប្រទេសជាតិឲ្យមាន អត្ថិភាពគ្រប់បែបយ៉ាង សំរាប់ការពារឯករាជភាព និងបូរណភាពទឹកដីជាតិនៅចំពោះមហិច្ឆិតាបរទេស។ យើងដឹងថា ទោះបីមេឃរលំ ភ្នំរលាយ បើសិនណាប្រទេសខ្មែរ នៅតែខ្សោយក្រលំបាក ប្រទេសជិតខាងយើងនៅតែ វាតទឹកដីដដែល តាមមធ្យោបាយថ្មីគឺ “ធ្វើអាណានិគម តាមរយៈ សេដ្ឋកិច្ច” ព្រោះជាក្រឡារស់ សំរាប់ប្រជាពលរដ្ឋរបស់គេ។
រដ្ឋមានភារៈកិច្ចការពារប្រយោជន៍សាធារណៈ ឬការបំរើសាធារណៈជន។ ប្រយោជន៍នេះជាតម្លៃ សំខាន់បំផុតរបស់ជាតិ ហេតុនេះបានជាយើងសន្មត់ថា គ្មាននរណាមកតន្លៃ លក់ចេញ-ទិញដូរ ឬ បំបាត់បាន ដោយបំភ្លេចចោលនោះឡើយ។
សម្បត្តិជាតិដែលកើតអំពីអភិវឌ្ឍន៍សេដ្ឋកិច្ច មិនត្រូវក្លាយជាឱកាសមួយ ដើម្បីឲ្យអ្នកស្រេកអំណាច និង ឃ្លានទ្រព្យកេញប្រវ័ញ យកធ្វើ មាន-បាន តែម្នាក់ឯង ហើយនាំឲ្យមានការឈ្លោះបែកបាក់គ្នា មិនចេះចប់។ រីឯស្រុកខ្មែរ ក៏នឹងប្រេះឆា វិនាសអន្តរាយមិនខាន។ សម្បត្តិជាតិ នេះត្រូវយកមក ធ្វើជាធនធានសំរាប់ ៖ ១-អប់រំយុវជននិងប្រជាជនខ្មែរ ឲ្យមានគុណសម្បត្តិខាងបញ្ញា ខាងវិទ្យាសាស្ត្រ ខាងបច្ចេទេស, ២-សំរាប់ប្រើមធ្យោបាយ កាត់បន្ថយវិសមភាព (ភាពមិនស្មើគ្នា) រវៀង អ្នកមាននិងអ្នកក្រ និងបំបាត់ អយុត្តិធម៌ ក្នុងសង្គម, ៣-សំរាប់អភិវឌ្ឍន៍នយោបាយ សាធារណសុខាភិបាល សំរាប់ប្រជាជនខ្មែរ។

**<u>សេចក្ដីសន្និដ្ឋាន</u>** :
ការអភិវឌ្ឍន៍សេដ្ឋកិច្ចឲ្យជឿនលឿន-ការអប់រំជាតិឲ្យមានកិរិតខ្ពង់ខ្ពស់-ការពារយុត្តិធម៌សង្គម ជាក់ស្តែង-ការពារគុណសម្បត្តិសាធារណៈ-និងការអនុវត្តយ៉ាងម៉ឺងម៉ាត់នូវលទ្ធិប្រជាធិបតេយ្យ ជាមធ្យោបាយប្រាំនាំសង្គមខ្មែរ លែងនៅជាសង្គមជិតស្លុង លង់ខ្លៅទៀតឡើយ។ ផ្ទុយទៅវិញជាសង្គមមានមានថាមពល អាចទទួលអំពីពិភពលោកនូវការចំរើនគ្រប់ប្រការ។ យើងធ្វើសន្និដ្ឋានបានថាការអនុវត្តិទាំងប្រាំនេះគឺជាមធ្យោបាយថែរក្សានិងការពារជាតិខ្មែរនោះហើយ។ **បារមីស្រុកឋិតនៅលើសុភមង្គលនៃខេមរៈបុត្រម្នាក់ៗ** (នេះជាសំដីលោកបណ្ឌិត ឌុគ រាស៊ី)។

ថ្ងៃទី២០ ខែមិថុនា ឆ្នាំ ២០១០
អ៊ុប សៅ សង្ហា